# បញ្ជីសំរាប់ផែ្ទកមើលសុខភាពនិងសន្តិសុខនៃមណ្ឌល

បញ្ជីសំរាប់ផែ្ទកមើលនេះផ្តល់ជូនឳពុកម្តាយនូវបញ្ជីនៃសំណួរដែលជាយោបល់ដើម្បីសួរអ្នកផ្តល់កិច្ចថែរក្សាក្មេងរបស់គេ ដើម្បីធ្វើឱ្យប្រាកដថាផ្ទះដែលជាកន្លែងផ្តល់កិច្ចថែរក្សាក្មេងជាកន្លែងមានសន្តិសុខនិងសុខភាពល្អសំរាប់កូនរបស់គេ ។ បញ្ជីនេះមិនមានបញ្ចូលនូវស្ថានភាពទាំងអស់ដែលអាចមានគ្រោះថ្នាក់ចំពោះកូនរបស់លោកអ្នកនោះឡើយ ។ បញ្ជីសំរាប់ផែ្ទកមើលនេះគឺជាពត៌មានបន្ថែមទៅលើសំណៅសេចក្តីថ្លែងការបញ្ជាក់ដោយខ្លួនឯងអំពីសុខភាពនិងសន្តិសុខ (Health & Safety Self-Certification), សំណៅលេខ CCP 4 ដែលត្រូវបានបំពេញដោយលោកអ្នក ហើយនិងអ្នកផ្តល់កិច្ចថែរក្សាក្មេងរបស់លោកអ្នក ។ គឺមិនមានការតម្រូវតាមច្បាប់ណាមួយសំរាប់ឱ្យអ្នកផ្តល់កិច្ចថែរក្សាក្មេងរបស់លោកអ្នកធ្វើតាមច្បាប់សុខភាពនិងសន្តិសុខនៅលើសំណៅនេះឡើយ ។ បើសិនជាអ្នកផ្តល់កិច្ចថែរក្សាក្មេងរបស់លោកអ្នកមិនដូចលក្ខណៈណាមួយ ឬច្រើននៅលើបញ្ជីសំរាប់ផែ្ទកមើលហើយគាត់មិនព្រមកែតម្រូវបញ្ហានោះទេ លោកអ្នកអាចស្វែងរកអ្នកផ្តល់កិច្ចថែរក្សាក្មេងដទៃទៀត ។ បើសិនជាលោកអ្នកត្រូវការឱ្យជួយ សូមសួរអ្នកកាន់សំណុំរឿងរបស់លោកអ្នក ឬភ្នាក់ងារផ្តល់ប្រភពនៃកិច្ចថែរក្សាក្មេងនិងណែនាំឱ្យទៅរក (Child Care Resource and Referral Agency) នៅក្នុងតំបន់របស់លោកអ្នក ។ សូមពិនិត្យបញ្ជីនេះសាឡើងវិញជាមួយអ្នកផ្តល់កិច្ចថែរក្សាក្មេងរបស់លោកអ្នកនៅក្នុងផ្ទះដែលគេនឹងផ្តល់កិច្ចថែរក្សា ។

## នៅក្នុងផ្ទះ

| មាន | ទេ | |
|---|---|---|
| ☐ | ☐ | តើកន្លែងដោតខ្សែអគ្គិសនីទាំងអស់មានគម្របការពារសន្តិសុខក្មេងឬទេ? |
| ☐ | ☐ | តើទឹកដែលបើកចេញពីក្បាលម៉ាស៊ីនទឹកមានកំដៅ១២០អង្សាហ្វារិនហៃ (Fahrenheit) ឬតិចជាងនេះឬទេ? |
| ☐ | ☐ | តើគ្រឿងកំដៅ បំពង់ទឹក ចង្ក្រានភ្លើងដុតកំដៅ ចង្ក្រានដុតឧសហើយនិងកន្លែងដែលមានផ្ទៃក្តៅដទៃទៀតបានគ្រប ដើម្បីការពារមិនឱ្យរលាកក្មេងឬទេ? |
| ☐ | ☐ | តើគេមានគ្របដង្ហាល់គ្រប់ប្រភេទឱ្យបានជិតល្អមដើម្បីការពារមិនឱ្យម្រាមដៃក្មេងតូចៗចូលបានឬទេ? |
| ☐ | ☐ | តើគេមានដាក់គន្លឹះថតតុ និងទូចានទាំងអស់ដែលមានរបស់នាំឱ្យមានគ្រោះថ្នាក់/គ្រឿងពុលដើម្បីការពារសន្តិសុខដែលក្មេងបើកមិនបានឬទេ? |
| ☐ | ☐ | តើគេបានដាក់គន្លឹះការពារបង្អួចមិនឱ្យបើកធំជាង៦អ៊ីនច៍ (inches) ឬទេ? |
| ☐ | ☐ | តើកន្លែងថែក្មេងមិនមានថ្នាំលាបមានជាតិសំណរ ជាតិនាំឱ្យពុលឬថ្នាំលាបរបេកឬទេ? |
| ☐ | ☐ | បើសិនជាទ្វារអាចចាក់សោពីខាងក្នុង តើគេបានប្រើបង់ស្អិតបិទគន្លឹះកុំឱ្យចាក់សោបាន ដោះគន្លឹះចេញ ឬក៏ដាក់កូនសោនៅខាងក្រៅបន្ទប់ឬទេ? |
| ☐ | ☐ | បើសិនជាគេប្រើហិបដាក់ប្រដាប់ក្មេងលេង តើគេបានដោះយកគម្របចេញ ឬក៏ចោះប្រហោងឱ្យខ្យល់ចេញចូលបាន និងដាក់គន្លឹះដែលនាំឱ្យគម្របបិទដោយឃឹតៗឬទេ? |
| ☐ | ☐ | តើអ្នកផ្តល់កិច្ចថែរក្សាក្មេងដឹងថាគេត្រូវការលាងសំអាតដៃរបស់គេ នៅមុនពេលកាន់ឬចែកចាយម្ហូបអាហារ បន្ទាប់ពីបានចូលបន្ទប់ទឹក ឬបន្ទាប់ពីប្តូរកន្ទបក្មេងរួចមក? |

## ផ្លូវដើរក្នុងផ្ទះនិងជណ្តើរ

| មាន | ទេ | |
|---|---|---|
| ☐ | ☐ | តើផ្លូវដើរក្នុងផ្ទះនិងជណ្តើរមិនមានរបស់អ្វីដែលបណ្តាលឱ្យទាក់ដួលឬធ្លាក់ឬទេ? |
| ☐ | ☐ | តើនៅមាត់ជណ្តើរមានរនាំងការពារឬទេ? |
| ☐ | ☐ | តើរនាំងជណ្តើរមានប្រហោងតូចល្មមដើម្បីការពារកុំឱ្យជាប់ក្បាលក្មេងឬទេ? |

## ចង្ក្រាន

| មាន | ទេ | |
|---|---|---|
| ☐ | ☐ | តើកាំបិទ របស់ស្រួចឬមុតដទៃទៀត និងគ្រឿងប្រើប្រាស់ដែលអាចនាំឱ្យមានគ្រោះថ្នាក់ត្រូវបានដាក់នៅកន្លែងដែលក្មេងមិនអាចយកបានឬទេ? |
| ☐ | ☐ | តើដៃឆ្នាំងតែងតែដាក់បង្វែរទៅផ្នែកខាងក្រោយនៃចង្ក្រានឬទេ? |
| ☐ | ☐ | តើសម្ភារៈសំរាប់លាងសំអាតនិងគ្រឿងដែលមានជាតិពុលដទៃទៀតត្រូវបានទុកនៅក្នុងកន្លែងចាក់សោ ដែលក្មេងមិនអាចយកបានឬទេ? |
| ☐ | ☐ | តើសម្រាមត្រូវបានទុកនៅឆ្ងាយពីកន្លែងរៀបចំម្ហូបអាហារ និងកន្លែងទុកដាក់ម្ហូបឬទេ? |

## បន្ទប់ទឹក

| មាន | ទេ | |
|---|---|---|
| ☐ | ☐ | តើថ្នាំពេទ្យទាំងអស់ត្រូវបានទុកនៅក្នុងទូដោយមានដាក់គន្លឹះការពារដែលក្មេងមិនអាចយកបានឬទេ? |
| ☐ | ☐ | តើគេតែងតែបិទគម្របបង្គន់ឬទេ? |
| ☐ | ☐ | តើគ្រឿងប្រដាប់អគ្គិសនី ប្រដាប់ផ្លុំសក់ឱ្យស្ងួត ប្រដាប់កោរ ប្រដាប់ធ្វើឱ្យសក់រួញ ។ល។ ត្រូវបានទុកដាក់ឱ្យឆ្ងាយពីទឹក និងដែលក្មេងមិនអាចយកបានឬទេ? |

## នៅក្រៅផ្ទះ

| មាន | ទេ | |
|---|---|---|
| ☐ | ☐ | តើទីធ្លាសំរាប់ក្មេងលេងមានធ្វើរបងឬទេ បើសិនជានៅជិតកន្លែងដែលនាំឱ្យមានគ្រោះថ្នាក់ ដូចជាផ្លូវមានចរាចរមមាញឹកជាដើម? |
| ☐ | ☐ | បើសិនជាលោកអ្នកមានគ្រឿងប្រដាប់សំរាប់ក្មេងលេង(ដូចជាទោង កន្លែងរអិល ។ល។) តើកន្លែងលេងមានផ្ទៃទន់ជ្រាយដូចជាដីខ្សាច់ ឬកំទេចឈើឬទេ? |
| ☐ | ☐ | បើសិនជាមានអាងទឹកនៅក្នុងដី តើគេមានរបងព័ទ្ធជុំវិញអាងកំពស់៥ហ្វ៊ុត (Foot) ដែលអាចមើលឃើញខាងក្នុង ដោយមានទ្វារដាក់គន្លឹះដោយខ្លួនឯងនៅពេលបិទដែលគន្លឹះនោះនៅខាងលើ ឬក៏មានគម្របដែលជាប់មាំអាចធារទៅនឹងទម្ងន់នៃមនុស្សចាស់ម្នាក់ឬទេ? |
| ☐ | ☐ | តើគេមានការត្រួតពិនិត្យជានិច្ចចំពោះក្មេងដែលនៅជិតទឹកឬទេ? |

## រថយន្ត

| មាន | ទេ | |
|---|---|---|
| ☐ | ☐ | បើសិនជាអ្នកផ្តល់កិច្ចថែរក្សាក្មេងមានការអនុញ្ញាតឱ្យដឹកនាំក្មេង តើរថយន្តមានខ្សែក្រវ៉ាត់កៅអី និងកៅអីរថយន្តសំរាប់ក្មេងត្រឹមត្រូវសំរាប់ទំហំ និងអាយុនៃក្មេងឬទេ? |

## ការមានអាសន្ន

| មាន | ទេ | |
|---|---|---|
| ☐ | ☐ | តើអ្នកផ្តល់កិច្ចថែរក្សាក្មេងមានដឹងអំពីបញ្ហាផ្នែកសុខភាពអ្វីមួយដែលកូនរបស់លោកអ្នកអាចមានឬទេ? |
| ☐ | ☐ | តើនៅក្នុងផ្ទះមានទូរស័ព្ទដែលអាចប្រើការបានសំរាប់ទាក់ទងនៅពេលមានអាសន្នឬទេ? |
| ☐ | ☐ | តើនៅក្នុងផ្ទះមានប្រដាប់បន្លឺសញ្ញានៅពេលមានផ្សែងប្រើការបានមួយយ៉ាងតិច និងប្រដាប់ពន្លត់ភ្លើងឬទេ? |
| ☐ | ☐ | បើសិនជាមានកាំភ្លើង តើរបស់ទាំងនេះត្រូវបានចាក់សោទុក និងគ្រាប់រំសេវត្រូវបានចាក់សោទុកដោយឡែកនៅក្នុងកន្លែងទុកដាក់មួយឬទេ? |
| ☐ | ☐ | តើអ្នកផ្តល់កិច្ចថែរក្សាដឹងអំពីសិទ្ធិនៃឪពុកម្តាយដើម្បីចូលក្នុងផ្ទះ និងជួបជាមួយកូនរបស់គេបានគ្រប់ពេល នៅក្នុងពេលដែលកិច្ចថែរក្សាកំពុងតែផ្តល់ឱ្យឬទេ? |
| ☐ | ☐ | តើគេមានគ្រឿងបរិក្ខារជួយជាបន្ទាន់សំរាប់ពេលមានអាសន្នឬទេ? |
| ☐ | ☐ | តើអ្នកផ្តល់កិច្ចថែរក្សាក្មេងមានផែនការសំរាប់រត់ចេញនៅពេលមានអាសន្នឬទេ? |
| ☐ | ☐ | តើអ្នកផ្តល់កិច្ចថែរក្សាក្មេងរក្សានូវប័ណ្ណព័ត៌មាននៅពេលមានអាសន្នសំរាប់ក្មេងនីមួយៗ ដោយមានឈ្មោះពេញរបស់ក្មេង លេខទូរស័ព្ទ និងទីកន្លែងនៃឪពុកម្តាយ ឬមនុស្សពេញវ័យដែលជាអ្នកទទួលខុសត្រូវដទៃទៀតដែលបានផ្តល់ឈ្មោះដោយឪពុកម្តាយ សំរាប់ជួបនៅពេលមានអាសន្ន ឈ្មោះនិងលេខទូរស័ព្ទនៃគ្រូពេទ្យរបស់ក្មេង និងសេចក្តីអនុញ្ញាតយល់ព្រមរបស់ឪពុកម្តាយសំរាប់ការផ្តល់នូវកិច្ចថែរក្សាផ្នែកពេទ្យនៅពេលមានអាសន្នឬទេ? |